# សេចក្តីផ្តើម

ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីមានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ ។ បណ្តឹងរដ្ឋប្បវេណីដោះស្រាយវិវាទភាគីដោយបង្ខំ ភាគីផ្ទាល់ឲ្យគេគោរពតាមសេចក្តីសម្រេចរបស់តុលាការ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយរដ្ឋបង្កើតប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីនេះឡើង មិនមែនក្នុងគោលបំណងធ្វើការដោះស្រាយវិវាទនោះឯងទេ តែគឺដើម្បីធ្វើការទទួលស្គាល់តាមរយៈតុលាការថាបុគ្គលម្នាក់មានសិទ្ធិស្របច្បាប់ និងដើម្បីការពារសិទ្ធិរបស់បុគ្គលនោះដោយបញ្ចប់នូវវិវាទ ។

ការការពារសិទ្ធិតាមរយៈនីតិវិធីរដ្ឋប្បវេណីមិនមែនជាការដាក់ទានពីរដ្ឋទៅឲ្យប្រជាជននោះទេ ផ្ទុយទៅវិញគេត្រូវយល់ថា បុគ្គលឯកជនគ្រប់រូប មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីស្វែងរកការការពារសិទ្ធិរបស់ខ្លួន ល្គឹកណាដែលសិទ្ធិនោះត្រូវបានគេបំពាន នៅក្នុងវិវាទរដ្ឋប្បវេណី ។ អាស្រ័យហេតុនេះហើយគេអាចនិយាយបានថាសិទ្ធិពឹងពាក់តុលាការ គឺជា"សិទ្ធិមូលដ្ឋានដើម្បីធានានូវសិទ្ធិមូលដ្ឋាន និងសិទ្ធិផ្សេងៗទៀត" ។

ជាការពិតណាស់នៅពេលវិវាទមួយកើតឡើងហើយឈានដល់ការដោះស្រាយដោយប្រព័ន្ធតុលាការ នោះយើងត្រូវធ្វើការសិក្សាលើនីតិវិធីនៃបណ្តឹងដែលមានជាដំណាក់កាលៗក្នុងការអនុវត្តដោយអនុលោមតាមច្បាប់ពោលគឺក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ យើងឃើញថានីតិវិធីនៃបណ្តឹងមានច្រើនដំណាក់កាល និងមានភាពស្មុំញ៉ាំច្រើន ។ ទោះបីជាយ៉ាងណាក៏ដោយពេលដែលនីតិវិធីកំពុងតែដំណើរការក៏មានលេចចេញនូវនីតិវិធីមួយដែរគឺការផ្អាក និងការបង្អង់នីតិវិធីបណ្តឹង ដែលវាបណ្តាលមកពីមូលហេតុមួយចំនួន ដែលច្បាប់កំណត់ ដែលបានជះឥទ្ធិពលដល់ដំណើរការរឿងក្តីរដ្ឋប្បវេណី ។

ដូចនេះយើងនឹងសាកល្បងដើម្បីធ្វើការសិក្សា លើចំនុចនេះពោលគឺសិក្សាអំពីមូលហេតុ និងអានុភាពនៃការផ្អាកនីតិវិធីបណ្តឹង (ផ្នែក ទី១) និងមូលហេតុ និងអានុភាពនៃការបង្អង់នីតិវិធីបណ្តឹង (ផ្នែក ទី២) ដូចខាងក្រោក ។

# ផ្នែកទី ១ ៖ ការផ្អាកនីតិវិធីបណ្តឹង

ការផ្អាកនីតិវិធីបណ្តឹង សំដៅដល់ស្ថានភាពមួយដែលដំណើរការនៃរឿងក្តីរដ្ឋប្បវេណីមួយត្រូវបានបញ្ឈប់ជាបណ្តោះអាសន្នដោយសារទទួលរងនូវហេតុការណ៍ណាមួយដែលនាំឲ្យមានការផ្លាស់ប្តូរនូវលក្ខណៈរបស់ភាគី ឬភាគីត្រូវបានបាត់បង់សមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងជា អាទិ៍ ។

គេសង្កេតឃើញថា ស្ថានភាពនៃការផ្អាកនីតិវិធីបណ្តឹង គឺកើតចេញពីការកំណត់របស់ច្បាប់ដែលបានបញ្ជាក់អំពីមូលហេតុនានាដែលមានអនុភាពនាំឲ្យនីតិវិធីបណ្តឹងនេះអាចផ្អាកបាន(១) ក៏ប៉ុន្តែមិនមានន័យថា បណ្តឹងនោះត្រូវបញ្ចប់នោះទេ គ្រាន់តែផ្អាកបណ្តោះអាសន្ន ហើយអានុភាពរបស់វា គឺទទួលបន្តនូវការអនុវត្តនីតិវិធីបណ្តឹងនោះ (២) ។

## ១. មូលហេតុនៃការផ្អាកនីតិវិធីបណ្តឹង និងអ្នកទទួលបន្តនីតិវិធីបណ្តឹង

ការដែរចែងអំពីមូលហេតុនៃការផ្អាកនូវនីតិវិធីបណ្តឹង គឺដើម្បីរងចាំរហូតដល់ភាគីថ្មីអាចមានបធ្យោបាយតទល់ និងការពារខ្លួន ដើម្បីធានានូវសិទ្ធិរបស់ភាគីចំពោះនីតិវិធីបាន ។ អំពីមូលហេតុនៃការផ្អាកនីតិវិធីបណ្តឹងមានចែងក្នុងមាត្រា ១៧៣ កថាខ័ណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ ដែលក្នុងមាត្រានេះមានបញ្ជាក់ចំនួន ៥ ចំណុចដូចខាងក្រោម ៖

### ក. មរណភាពរបស់ភាគី

ដូចដែលមានកំណត់នៅក្នុងច្បាប់សារធាតុ ពោលក្រមរដ្ឋប្បវេណី បុគ្គលម្នាក់បាត់បង់សមត្ថភាពរបស់ខ្លួន(សមត្ថភាពទទួលបានសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព) នៅពេលដែលបុគ្គលនោះទទួលមរណភាពយ៉ាងពិតប្រាកដ ប៉ុន្តែច្បាប់ក៏បានកំណត់អំពីការទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចមួយចំនួមនទៅដល់បុគ្គលផ្សេងទៀតបានដែរ ដូចជា សន្តិជន ជាដើម ។ ដូចនេះនៅក្នុងដំណើរការនៃកិច្ចនីតិវិធីនៃបណ្តឹងក៏ដូចគ្នាផងដែរ បើភាគីណាមួយបានទទួលនូវមរណភាពនោះយើងឃើញថា ភាគីមួយនោះពុំអាចចូលរួមមកតទល់តទៅទៀតចំពោះភាគីម្ខាងទៀត ដែលករណីនេះត្រូវរងចាំរហូតដល់មានអ្នកតំណាងណាមួយដែលត្រូវបានតុលាការទទួលស្គាល់។ ចំពោះសិទ្ធិតំណាងដោយអាណត្តិ ទោះបីជាភាគីបានទទួលមរណភាពក៏ដោយក៏សិទ្ធិតំណាងនេះមិនរលត់ទេ ហើយអ្នកតំណាងនោះនឹងក្លាយទៅជាអ្នកតំណាងដោយអាណត្តរបស់សន្តិជន ឬ អ្នកអាណាព្យាបាលទូទៅជាអាទិ៍ ។ ប៉ុន្តែក្នុងរឿងក្តីខ្លះមរណភាពរបស់ភាគីមិនមែនជាមូលហេតុដែលនាំឲ្យមានការផ្អាកនីតិវិធីនោះទេ គឺមានន័យថានីតិវិធីបណ្តឹងនោះត្រូវតែបញ្ចប់តែម្តង

ដោយស្វ័យប្រវត្តិ ពោលដូចជា រឿងក្ដីលែងលះ ព្រោះថាប្រភេទនៃរឿងក្ដីនេះពុំមានបុគ្គលណាផ្សេងទៀតអាចទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទាំងនេះបាននោះទេ ។

ចំពោះការទទួលបន្តនូវបណ្ដឹង ជាគោលការណ៍ សន្តតិជនជាអ្នកទទួលបន្តបណ្ដឹង ប៉ុន្តែក្នុងអំឡុងពេលដែលសន្តតិជនអាចបោះបង់ចោលនូវសន្តតិកម្ម សន្តតិជនក៏មិនទាន់បានកំណត់ឡើយ ហេតុនេះហើយ មិនអាចបន្តបណ្ដឹងបានទេ ។ បុគ្គលដែលត្រូវបន្តបណ្ដឹងតាមច្បាប់ ឬ បទដ្ឋានផ្សេងទៀតគឺដូចជាអ្នកដែលតុលាការចាត់តាំងដើម្បីគ្រប់គ្រងមត៌ក ក្នុងករណីដែលគ្មានសន្តតិជនជាដើម។

ប៉ុន្តែក្នុងករណីដែលគ្មានអ្នកទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះនីតិវិធីត្រូវបញ្ចប់ ក្នុងករណីនេះតុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្ដឹងនោះ(១៧៤)។

**ខ. ការរលត់នីតិបុគ្គលដែលជាភាគី ដោយការរួមបញ្ចូលនីតិបុគ្គល**

នីតិបុគ្គលសំដៅដល់ក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច ។ អាស្រ័យដូចនេះ នីតិបុគ្គលមានបុគ្គលភាពគតិយុត្តិដូចរូបវន្តបុគ្គលផងដែរ ក្នុងការនោះក៏មានសមត្ថភាពក្នុងធ្វើសកម្មភាពបណ្ដឹងផងដែរ ដូចមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។ ម្យ៉ាងវិញទៀត នីតិបុគ្គលក៏អាចត្រូវរលត់ដោយមូលហេតុណាមួយផងដែរ។ ក្នុងករណីនេះ ប្រសិនបើនីតិបុគ្គលនោះត្រូវបានរលត់ដោយសារការរួមបញ្ចូលជាមួយនឹងនីតិបុគ្គលផ្សេងទៀត ប៉ុន្តែនីតិបុគ្គលនោះកំពុងតែមានរឿងក្នុងតុលាការដែលដំណើរការកិច្ចនីតិវិធីកំពុងបន្ត ដែលធ្វើសកម្មភាពដោយអ្នកតំណាងណាមួយរបស់ខ្លួន ស្ថិតក្នុងស្ថានភាពបែបនេះ ច្បាប់បានកំណត់ហើយថានីតិវិធីបណ្ដឹងត្រូវផ្អាក ។ ក្នុងករណីនៃការរួមបញ្ចូលនឹងនីតិបុគ្គល នីតិបុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ច ទូទៅទាំងអស់ក្រោយពេលរួមបញ្ចូល ត្រូវទទួលបន្តនីតិវិធីនៃបណ្ដឹងនោះ ។

ប៉ុន្តែក្នុងករណីដែលសិទ្ធិ និងកាតព្វកិច្ច នោះបានធ្លាក់ទៅលើបុគ្គលតែម្នាក់ នោះនីតិវិធីត្រូវបញ្ចប់ ក្នុងករណីនេះតុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្ដឹងនោះ(១៧៤) ។

**គ. ការបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្ដឹងរបស់ភាគី ឬ មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬការរលត់នូវសិទ្ធិតំណាង**

សមត្ថភាពក្នុងការធ្វើបណ្ដឹង គឺជាល័ក្ខខណ្ឌសុពលភាពនៃសកម្មភាពបណ្ដឹងនីមួយៗ ហើយសកម្មភាពរបស់ជនដែលគ្មានសមត្ថភាពក្នុងធ្វើបណ្ដឹងគឺជាសកម្មភាពមោឃៈ។ ករណីនេះខុសគ្នានឹងករណីដែលមានកង្វះសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងតាមក្រមរដ្ឋប្បវេណី ដែលចែងថាសកម្មភាពមានសុពលភាពរហូតដល់ពេលដែលមានការលុបចោល។ នេះគឺដោយសារតែដើម្បីឲ្យ

មានស្ថិរភាពក្នុងនីតិវិធី ។ តុលាការត្រូវធ្វើការស្រាវជ្រាវអំពីអត្ថិភាព ឬនត្ថិភាពនៃសមត្ថភាពក្នុងការធ្វើបណ្តឹង ដោយឆន្ទានុសិទ្ធិពេលណាក៏ដោយ ។

ទោះជាសកម្មភាពបណ្តឹងរបស់ជនដែលខ្វះសកម្មភាពក្នុងការធ្វើបណ្តឹងក៏ដោយ មិនមែនមានន័យថា ជននោះបាត់បង់នូវផលប្រយោជន៍រាល់ពេលនោះទេ ហេតុនេះហើយ ប្រសិនបើអ្នកតំណាងដែលច្បាប់កំណត់ ឬភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងវិញ បានផ្តល់សច្ចានុមតិ សកម្មភាពនោះនឹងមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះត្រូវបានធ្វើ ឡើង (ម. ៣៥ កថាខណ្ឌទី២) ។

តាមលទ្ធផលនៃការស្រាវជ្រាវ ទោះជាតុលាការឃើញថា ភាគីពុំមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងក៏ដោយ ក៏អាចមានការផ្តល់នូវសច្ចានុមតិ ដូច្នេះហើយមិនត្រូវបដិសេធសកម្មភាពភ្លាមៗទេ ត្រូវបង្គាប់ឲ្យធ្វើការកែតម្រូវដោយកំណត់អំឡុងពេលមួយ។ ក្នុងករណីដែលបានបង្គាប់ឲ្យធ្វើការកែតម្រូវ ត្រូវផ្អាកនូវនីតិវិធីរហូតដល់អំឡុងពេលសម្រាប់កែតម្រូវនោះបានកន្លងផុតទៅ។ ក៏ប៉ុន្តែសកម្មភាពណាមួយដែលតុលាការអាចឲ្យធ្វើសកម្មភាពនោះជាបណ្តោះអាសន្នបាន។

ក្នុងករណីដែលកង្វះនូវសមត្ថភាពក្នុងការធ្វើបណ្តឹងកើតមានឡើង ក្រោយពេលចាត់ការបណ្តឹងនោះ ត្រូវផ្អាកនីតិវិធីបណ្តឹងនោះ ហើយអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវទទួលបន្តប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់បានទទួលមរណភាព ឬ បានបាត់បង់នូវសិទ្ធិតំណាងភាគីនៅដដែល ប៉ុន្តែមានបញ្ហាក្នុងការធានាសិទ្ធិរបស់ភាគីចំពោះនីតិវិធីប្រសិនបើធ្វើនីតិវិធីបន្តទៅទៀត។ ហេតុនេះត្រូវផ្អាកនីតិវិធីបណ្តឹង ហើយអ្នកតំណាងដែលច្បាប់បានកំណត់ថ្មីត្រូវទទួលបន្ត ឬក្នុងករណីដែលសមត្ថភាពនៃភាគីបានស្តារឡើងវិញ ហើយអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវរលត់នោះសាមីខ្លួនជាអ្នកទទួលបន្តបណ្តឹង ។

ទោះបីជាតុលាការបានចេញសាលក្រមនៃការជម្រះក្តីលើកទីមួយ ដោយមិនបានដឹងពីអសមត្ថភាពនៃការធ្វើបណ្តឹងរបស់ភាគី ភាគីម្ខាងណាក៏អាចទាមទារឲ្យលុបចោលសាលក្រមឬសាលដីកានោះតាមរយៈបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន។ ម្យ៉ាងទៀត ទោះជាសាលក្រម ឬសាលដីកាបានចូលជាស្ថាពរក៏ដោយ ក៏អាចទាមទារឲ្យលុបចោលសាលក្រម ឬសាលដីកានោះតាមរយៈបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មីបានដែរ។

**ឃ. មរណភាព ឬការបាត់បង់នូវលក្ខណៈសម្បត្តិដោយមូលហេតុផ្សេងរបស់បុគ្គលដែលមានលក្ខណសម្បត្តិដែលបានកំណត់ ហើយធ្វើបណ្ដឹងក្នុងនាមផ្ទាល់ខ្លួន ជំនួសអ្នកដទៃ**

ក្នុងករណីដែលជនមានលក្ខណសម្បត្តិជាភាគីតាមផ្លូវច្បាប់ដោយមានលក្ខណៈដែលបានកំណត់ ហើយទទួលបន្ទុកបណ្ដឹងតាមច្បាប់(ឧ. អ្នកអនុវត្តមតកសាសន៍ ក្នុងករណីមានមតកសាសន៍) ហើយបុគ្គលនោះបានបាត់បង់នូវលក្ខណៈសម្បត្តិនោះ( ឧ. ករណីដែលអ្នកអនុវត្តមតកសាសន៍បានសុំលាលែង) នីតិវិធីនៃបណ្ដឹងត្រូវផ្អាក ហើយអ្នកដែលទទួលភារកិច្ចបន្ត ជាអ្នកទទួលបន្តបណ្ដឹងនោះ ។

**ង. មរណភាព ឬការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់ភាគីដែលត្រូវបានជ្រើសរើសទាំងអស់ ដោយបញ្ញត្តិនៃមាត្រ ៤២ (ការជ្រើសរើសភាគី) នៃក្រមនេះ**

ក្នុងករណីដែលភាគីបានជ្រើសរើសខ្លះ បានទទួលមរណៈភាព ឬបានបាត់បង់នូវលក្ខណៈសម្បត្តិ ដោយបញ្ញត្តិនៃមាត្រា ៤២ (ការជ្រើសរើសភាគី) អ្នកដែលត្រូវបានជ្រើសរើសផ្សេងអាចធ្វើសកម្មភាពបណ្ដឹងបាប ប៉ុន្តែក្នុងករណីដែលភាគីត្រូវបានជ្រើសរើសទាំងអស់ទទួលមរណភាព ឬបានបាត់បង់នូវលក្ខណៈសម្បត្តិ ត្រូវផ្អាកនូវនីតិវិធីនៃបណ្ដឹង ហើយភាគីដែលត្រូវបានជ្រើសរើសាជាថ្មីត្រូវបន្ត ឬបើមិនបានធ្វើការជ្រើសរើសថ្មីទេ អ្នកដែលធ្វើការជ្រើសរើសត្រូវទទួលបន្តនូវបណ្ដឹងនោះ ក្នុងករណីដែលមានកើតមូលហេតុដូចដែលបានរៀបរាប់ខាងលើនេះ ប៉ុន្តែបើមានអ្នកតំណាងដោយអាណត្តិសម្រាប់ភាគីដែលមានមូលហេតុនោះ ទោះបីជាបន្តនីតិវិធីបណ្ដឹងក៏ដោយ ក៏អ្នកតំណាងដោយអាណត្តិនោះអាចអនុវត្តមធ្យោបាយតទល់ និងការពារខ្លួនបានត្រឹមត្រូវដែរ ហេតុនេះហើយគ្មានបញ្ហាទេ។ ហេតុដូច្នេះហើយក្នុងករណីដែលមានតំណាងដោយអាណត្តិ មិនត្រូវផ្អាកនីតិវិធីបណ្ដឹងទេ។ ប៉ុន្តែទោះក្នុងករណីនេះក៏ដោយ ក៏នៅតែមានសេចក្ដីចាំបាច់ក្នុងការរាយការណ៍ទៅតុលាការអំពីមូលហេតុខាងលើនេះដែរ ហេតុដូច្នេះហើយកថាខណ្ឌ ទី ២ ចែងអំពីករណីកិច្ចរបស់អ្នកតំណាងដោយអាណត្តិក្នុងការរាយការណ៍នោះ។

**២. នីតិវិធីដើម្បីទទួលបន្ត**

ចំពោះនីតិវិធីដើម្បីទទួលបន្តនូវបណ្ដឹង មានកំណត់ក្នុងមាត្រា ១៧៥ ។ ជាដំបូង បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំទទួលបន្តបណ្ដឹងជាភាគីម្ខាងទៀតនៃភាគីដែលមានហេតុផ្អាកនីតិវិធី ដូចជាបានទទួលមរណភាពជាដើម ឬបុគ្គលដែលមានលក្ខណៈទទួលបន្តដូចមានចែងក្នុងមាត្រា ១៧៣ ជាដើម ។ ភាគីម្ខាងទៀតក៏មានផលប្រយោជន៍ដែរក្នុងការជំរុញឲ្យនីតិវិធីបណ្ដឹងនោះឲ្យបានលឿន ហេតុនេះហើយបានជាមានសិទ្ធិដាក់ពាក្យសុំឲ្យបន្តនូវនីតិវិធីនេះដែរ ។ ពេលណាមានពាក្យសុំ

តុលាការត្រូវជូនដំណើង ។ ប្រសិនបើពាក្យសុំនេះត្រូវបានធ្វើឡើងដោយអ្នកមានលក្ខណៈទទួលពាក្យបន្តបណ្តឹង តុលាការត្រូវជូនដំណឹងទៅភាគីម្ខាងទៀត រីឯចំពោះពាក្យសុំរបស់ភាគីវិញត្រូវជូនដំណឹងទៅបុគ្គលដែលមានលក្ខណៈទទួលបន្តបណ្តឹងនោះ (ម្យ៉ាងទៀត បើភាគីម្ខាងទៀតដាក់ពាក្យបណ្តឹងសុំឲ្យទទួលស្គាល់បន្ត ភាគីនោះត្រូវកំណត់បុគ្គលដែលមានលក្ខណៈទទួលបន្ត)។ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវការទទួលបន្តបណ្តឹងនេះ គឺជាការសម្រេចសេចក្តីអំពីនីតិវិធីបណ្តឹង ហេតុនេះហើយត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ហើយត្រូវសម្រេចដោយដីការសម្រេច ។ បើសិនជាស្រាវជ្រាវទៅឃើញថា គ្មានមូលហេតុទទួលបណ្តឹងបានទេ តុលាការត្រូវលើកចោលនូវពាក្យសុំនោះ ហើយបើយល់ឃើញថាមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីការសម្រេចឲ្យទទួលបន្តនូវបណ្តឹងនោះ ។ ម្យ៉ាងទៀតប្រសិនបើការផ្អាកបណ្តឹងបានកើតឡើងក្រោយការបញ្ជូនសាលក្រមហើយ តុលាការដែលបានចេញសាលក្រមនោះត្រូវទទួលខុសត្រូវក្នុងការទទួលពាក្យសុំទទួលបន្ត និងក្នុងការសម្រេចសេចក្តីអំពីពាក្យសុំនោះ មិនមែនតុលាការដែលត្រូវទទួលបណ្តឹងឧទ្ធរណ៍ទេ (ក្រោយការប្តឹងឧទ្ធរណ៍តុលាការដែលទទួលបណ្តឹងត្រូវចេញដីការសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតការទទួលបន្ត ) ។

ទោះបីជាភាគីទាំងសងខាងមិនបានដាក់ពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹងក៏ដោយ ក៏តុលាការអាចបង្គាប់ឲ្យបន្តនីតិវិធីនៃបណ្តឹងដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយដីការសម្រេចបាន ដែរ (ម.១៧៦) ។ ចំពោះដំណើរការនៃនីតិវិធីបណ្តឹងជាគោលការណ៍ តុលាការត្រូវជម្រុញដំណើរការនៃនីតិវិធីនោះដោយឆន្ទានុសិទ្ធិរបស់ខ្លួន ហេតុនេះប្រសិនបើពិតជាមានអ្នកមានលក្ខណៈបន្ត បណ្តឹងតែគ្មានពាក្យសុំទទួលបន្តទាំងពីបុគ្គលដែលមានលក្ខណៈ និងទាំងពីភាគីម្ខាងទៀតទេ នោះតុលាការអាចបង្គាប់ឲ្យបន្តនីតិវិធីនៃបណ្តឹងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

**៣. អានុភាពនៃការផ្អាកនីតិវិធីបណ្តឹង**

ការផ្អាកនីតិវិធីបណ្តឹង គឺជារបបមួយដើម្បីធានានូវសិទ្ធិរបស់ភាគីចំពោះនីតិវិធីបណ្តឹង ហេតុនេះហើយបានជាពេលដែលនីតិវិធីនៃបណ្តឹងត្រូវផ្អាក ជាគោលការណ៍សកម្មភាពបណ្តឹងមិនអាចធ្វើបានទេ ហើយអំឡុងពេលក៏មិនត្រូវឲ្យដើរដែរ ។ ហេតុដូចនេះ សកម្មភាពបណ្តឹងដែលបានធ្វើឡើងនៅពេលដែលនីតិវិធីត្រូវផ្អាក ជាគោលការណ៍ត្រូវចាត់ទុកជាមោឃៈ ប៉ុន្តែចំពោះការប្រកាសសាលក្រមវិញមិនបាច់គឺតដល់សិទ្ធិរបស់ភាគីចំពោះនីតិវិធីទេ ហើយច្បាប់ចែងទាមទារថាឲ្យធ្វើការប្រកាសឲ្យឆាបរហ័ស ហេតុនេះហើយ ទោះបីជាពេលកំពុងផ្អាកនីតិវិធីក៏ដោយ ក៏អាចធ្វើការប្រកាសសាលក្រមបានដែរ ។ ក្រៅពីនេះសកម្មភាពរបស់តុលាការមួយចំនួនដូចជាដីការសម្រេចឲ្យទទួល

បន្តនីតិវិធី ការដកខ្លួនរបស់ចៅក្រម ជាដើម និងសកម្មភាពរបស់ភាគីមួយចំនួនដែលមិនប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ដូចជា ការដាក់ពាក្យសុំ ទទួលបន្តនីតិវិធី ការចាត់តាំងអ្នកតំណាងដោយអណត្តិ ពាក្យសុំជួយសង្គ្រោះលើបណ្តឹង ជាដើម អាចធ្វើបាន ។ ម្យ៉ាងទៀត អំឡុងពេលត្រូវបញ្ឈប់ដំណើរការ ហើយត្រូវចាប់ផ្តើមពីដំបូងវិញ ចាប់ពីពេលដែលបានបញ្ចប់នូវការផ្អាកនោះ ។ ឧ. ប្រសិនបើអំឡុងពេលដែលអាចប្តឹងឧទ្ធរណ៍ មាន ១ ខែ ហើយអំឡុងពេលនោះបានកន្លងផុត ៣ សប្តាហ៍ ហើយនៅសល់តែ ១សប្តាហ៍ទៀត ស្រាប់តែមានមូលហេតុដែលត្រូវផ្អាកពេលដែលមូលហេតុនេះបានរលត់ នោះអំឡុងពេលដើម្បីប្តឹងឧទ្ធរណ៍ត្រូវបានទទួលស្គាល់ ១ ខែទៀតដោយគិតចាប់ពីពេលរលត់ (មិនមែននៅសល់ ១ សប្តាហ៍នោះទេ) ។

## ផ្នែកទី២ ៖ ការបង្អង់នីតិវិធីបណ្តឹង

ការបង្អង់នីតិវីធិបណ្តឹង ក៍ជាស្ថានភាពមួយដែលនាំឲ្យមានការបញ្ឈប់ជាបណ្តោះអាសន្នផង ដែរ នូវនីតិវិធីបណ្តឹង ប៉ុន្តែមានមូលហេតុមួយចំនួនដែលខុសពីមូលហេតុដែលនាំឲ្យមានការផ្អាកនីតិវិធីបណ្តឹង មួយវិញទៀតគឺថាមិនឲ្យមានអ្នកបន្តនីតិវិធីបណ្តឹងនោះទេ តែមានភាពចាំបាច់តម្រូវឲ្យនីតិវិធីចប់មួយរយៈដើម្បីធានានូវសិទ្ធិរបស់ភាគីចំពោះនីតិវិធី នោះនីតិវិធីនៃបណ្តឹងត្រូវបាន បង្អង់ ។

**១. មូលហេតុនៃការបង្អង់នីតិវិធីបណ្តឹង**

យោងតាមមាត្រា ១៧៧ មានមូលហេតុមួយចំនួនដែលនាំតុលាការមិនអាចបំពេញការងាររបស់ខ្លួនដែលនាំឲ្យមានការបង្អង់នីតិវិធីបណ្តឹង ៖

**ក. គ្រោះមហន្តរាយធម្មជាតិ ឬ មូលហេតុផ្សេងទៀត**

ក្នុងករណីដែលតុលាការមិនអាចបំពេញកិច្ចការរបស់ខ្លួនបាន ដោយសារតំបន់ដែលជាទីតាំងនៃតុលាការនោះបានទទួលរងគ្រោះនូវមហន្តរាយធម្មជាតិ ដូចជា មហាអគ្គីភ័យ ទឹកជំនន់ ឬ ការរញ្ជួយផែនដី ឬ ក៏ដោយសារមានសង្គ្រាម សង្គ្រាមស៊ីវិលកុបកម្ម ជាដើម ។ អាស្រ័យហេតុនេះនីតិវិធីបណ្តឹងត្រូវតែបង្អង់តាមច្បាប់ ដោយមិនចាំបាច់មានការសម្រេចសេចក្តី ដោយតុលាការទេ ។ ចំពោះករណីផ្ទាល់ខ្លួនរបស់ចៅក្រមម្នាក់ មិនបញ្ចូលក្នុងករណីនេះ ។ ពេលណាមួយមូលហេតុដែលមានចែងខាងលើនេះត្រូវបានរលត់ ការបង្អង់នីតិវិធីក៏ត្រូវរលាយដែរ ហើយនីតិវិធីនៃបណ្តឹងក៏ត្រូវធ្វើបន្តទៀតដែរ ។ ប៉ុន្តែក្នុងករណីដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់គូភាគី តុលាការអាចផ្ទេរសមត្ថកិច្ចបានទៅតុលាការផ្សេងដែលមិនទទួលរងនូវគ្រោះធម្មជាតិ ឬហេតុការផ្សេងទៀតបានតាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ (ម.១៩) ។ ប៉ុន្តែការផ្ទេសមត្ថកិច្ចនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលបណ្តឹងស្ថិតនៅក្រោមសមត្ថកិច្ចផ្តាចមុខដែលបានកំណត់ដោយច្បាប់របស់តុលាការដែលចាត់ការលើបណ្តឹងនេះ ។

**ខ. ភាគីមិនអាចបន្តនីតិវិធីបណ្តឹងដោយសារឧបសគ្គមានរយៈពេលវែង ហើយមិនអាចប៉ាន់ស្មានបាន**

ប្រសិនបើភាគីដែលរស់នៅ មានឧបសគ្គក្នុងការធ្វើចរាចរដោយសារតែមានមហន្តរាយធម្មជាតិ ឬ ក៏ភាគីត្រូវបំបែកពីប្រជាជនធម្មតាដោសារមានជម្ងឺឆ្លង ជាដើម ដែលជាទូទៅ គេយល់ថាភាគីមិនអាចបន្តបណ្តឹងបាន ហើយដែលមិនអាចប៉ាន់ស្មាននូវពេលវេលាដែលមូនហេតុនោះរលត់ នោះនីតិវិធីនៃបណ្តឹងត្រូវបានបង្អង់ដែរ ដើម្បីការពារសិទ្ធិរបស់ភាគីចំពោះនីតិវិធី ។ ក្នុងករណីដែល

ភាគីបានធ្វើដំណើរលេង ឬ មានជម្ងឺតែមួយរយៈពេលជាដើម មិនបញ្ចូលក្នុងករណីនេះទេ ។ ក្នុងករណីនៃការបង្អង់នេះ តុលាការត្រូវបង្អង់នីតិវិធីដោយដីការសម្រេច ហើយពេលណាមូលហេតុបានរលត់ តុលាការក៏ត្រូវលុបចោលនូវដីការសម្រេចបង្អង់នោះដោយដីការសម្រេចដែរ ដើម្បីបន្តនីតិវិធីនៃបណ្តឹងទៀត ។ម្យ៉ាងទៀត ចំពោះដីការសម្រេចបង្អង់ ឬដីការសម្រេចលុបចោលការបង្អង់នេះ មិនអាចឧបាស្រ័យបានទេ ។

**គ. ករណីដែលរឿងក្តីព្រហ្មទណ្ឌកំពុងដំណើរការ**

មានន័យថារឿងក្តីរដ្ឋប្បវេណីកើតចេញពីអង្គហេតុនៃរឿងព្រហ្មទណ្ឌណាមួយ ។អាស្រ័យហេតុនេះនៅពេលដែលរឿងក្តីព្រហ្មទណ្ឌកំពុងដំណើរការ នោះអ្នករងគ្រោះដោយសាររឿងក្តីនោះអាចទាមទារឲ្យភ្ជាប់នូវការទាមទារសំណងរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌបាន ហើយក៏អាចដាក់ពាក្យបណ្តឹងនោះតាមបណ្តឹងរដ្ឋប្បវេណីធម្មតាបានដែរ ។ ប៉ុន្តែ ទោះក្នុងករណីពាក្យបណ្តឹងនោះតាមបណ្តឹងរដ្ឋប្បវេណីធម្មតាក៏ដោយ ក៏សាលក្រមព្រហ្មទណ្ឌដែលសម្រេចឲ្យទោសនោះ នឹងមានចំណងទៅលើបណ្តឹងរដ្ឋប្បវេណីដែរ ដែលតម្រូវឲ្យយើងគួរតែចែងថាអាចបង្អង់បាននូវដំណើរការនៃនីតិវិធីបណ្តឹងរដ្ឋប្បវេណីនោះ ។ តែបើយើងកំណត់ថា បណ្តឹងរដ្ឋប្បវេណីនោះត្រូវបានបង្អង់ដោយស្វ័យប្រវត្តិនោះ វានាំឲ្យមានគោលបំណងពន្យារបណ្តឹង ដែលអាចជាហេតុនាំឲ្យមានបណ្តឹងព្រហ្មទណ្ឌដែលមិនគួរឲ្យមានឡើយ ដូចនេះយោលទៅតាមការវិនិច្ឆ័យរបស់តុលាការ យើងបានចែងអំពីការអាចបង្អង់នូវនីតិវិធីនៃបណ្តឹងរបស់រឿងក្តីនោះបាន ។

**២. អានុភាពនៃការបង្អង់នីតិវិធីបណ្តឹង**

ដូចគ្នានឹងការផ្អាកនីតិវិធីបណ្តឹង ការបង្អង់នីតិវិធីបណ្តឹង គឺជារបបមួយដើម្បីធានានូវសិទ្ធិរបស់ភាគីចំពោះនីតិវិធីបណ្តឹង ហេតុនេះហើយបានជាពេលដែលនីតិវិធីនៃបណ្តឹងត្រូវបង្អង់កជាគោលការណ៍សកម្មភាពបណ្តឹងមិនអាចធ្វើបានទេ ហើយអំឡុងពេលក៏មិនត្រូវឲ្យដើរដែរ ។ ហេតុដូចនេះ សកម្មភាពបណ្តឹងដែលបានធ្វើឡើងនៅពេលដែលនីតិវិធីត្រូវបង្អង់ ជាគោលការណ៍ត្រូវចាត់ទុកជាមោឃៈ ប៉ុន្តែចំពោះការប្រកាសសាលក្រមវិញមិនបាច់គឹតដល់សិទ្ធិរបស់ភាគីចំពោះ នីតិវិធីទេ ហើយច្បាប់ចែងទាមទារថាឲ្យធ្វើការប្រកាសឲ្យឆាបរហ័ស ហេតុនេះហើយ ទោះបីជាពេលកំពុងបង្អង់នីតិវិធីក៏ដោយ ក៏អាចធ្វើការប្រកាសសាលក្រមបានដែរ ។ ក្រៅពីនេះសកម្មភាពរបស់តុលាការមួយចំនួនដូចជាដីការសម្រេចឲ្យទទួលបន្តនីតិវិធី ការដកខ្លួនរបស់ចៅក្រម ជាដើម និងសកម្មភាពរបស់ភាគីមួយចំនួនដែលមិនប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ដូចជា ការដាក់ពាក្យសុំទទួលបន្តនីតិវិធី ការចាត់តាំងអ្នកតំណាងដោយអណត្តិ ពាក្យសុំជួយសង្គ្រោះលើប

ណ្តឹងជាដើមអាចធ្វើបាន ។ ម្យ៉ាងទៀត អំឡុងពេលត្រូវបញ្ឈប់ដំណើរការ ហើយត្រូវចាប់ផ្តើមពីដំបូងវិញ ចាប់ពីពេលដែលបានបញ្ចប់នូវការបង្អង់នោះ ។ ឧ. ប្រសិនបើអំឡុងពេលដែលអាចប្តឹងឧទ្ធរណ៍ មាន ១ ខែ ហើយអំឡុងពេលនោះបានកន្លងផុត ៣ សប្តាហ៍ ហើយនៅសល់តែ ១សប្តាហ៍ទៀត ស្រាប់តែមានមូលហេតុដែលត្រូវផ្អាក ពេលដែលមូលហេតុនេះបានរលត់ នោះអំឡុងពេលដើម្បីប្តឹងឧទ្ធរណ៍ត្រូវបានទទួលស្គាល់ ១ ខែទៀតដោយគិតចាប់ពីពេលរលត់ (មិនមែននៅសល់ ១ សប្តាហ៍នោះទេ) ។